អូនជាមនុស្សបងស្នេហា

តែបងជាមនុស្សអូនស្អប់



០អារម្មតែមួយន័យខុសគ្នា

ទោះបីសុទ្ធជាអារម្មពិត

ស្រឡាញ់និងស្អប់គឺជាមិត្រ

មិនបានផលិតក៏កើតឯង។

ឱយតែមានស្នេហគង់មានស្អប់

មានផ្ដើមមានចប់សុខចំបែង

វដ្តស្នេហាចារទោះប្រឹងប្រែង

មិនអាចខ្នះខ្នែងចៀសវាងបាន...។

ឮតាមសារឈាមប្រហារស្នេហ

ចិត្តអូនប្រួលប្រែស្ដីក្លាហាន

បងមិនមែនមនុស្សដែលកល្យាណ

ស្នេហាឡើយកុំផានបងយល់ច្បាស់។

អានដូចស្ដាប់ឮពាក្យវរមិត្រ

គួរឱយអាណិតបេះដូងណាស់

ស្រឡាញ់សុខៗគេប្រែផ្លាស់

មេឃភ្លឺស្រលះស្រាប់តែភ្លៀង។

ភ្លៀងហើយមិនព្រមរាំងសោះឡើយ

មិនអស់មិនហើយក៏ស្នេហនាង

ក៏ធ្វើបាបចិត្តមិនព្រមរាង

នៅតែពោលច្រៀងរាល់ពាក្យស្នេហ។

ទាំងគេលែងចង់ស្តាប់បន្តិច

ក្តីស្នេហាទឹកលិចលង់ឥតល្ហែ

ដោកឈ្លក់បេះដូងនៅរស់ដែរ

មិនយូរគង់តែលង់មរណា។

ទោះអូនធ្លាប់ស្នេហាមិនសារភាព

មានតែបន្ទាបស្នេហាវៀមវ៉ា

ស្នេហាគេជួសបងមិនមេត្តា

ដល់ពាក្យរៀបការអូនធ្លាប់ប៉ង។

ទោះអូនស្តីអ្វីបងមិនប្រែ

នៅពេលពាក្យស្នេហាទាំងសៅហ្មង

ឃើញអូនមានថ្មីឈាមស្នេហាបង

ហូរមិនដាច់ម្តងគង់តែអស់។

អូនជាមនុស្សស្រីដែលបងស្នេហ

ទោះអូនបានប្រែក៏បងស្មោះ

ដឹងត្រឹមស្រឡាញ់ឱយលុះខ្យោះ

រហូតបង់បោះចិត្តស្នេហាបាន។

មិនដឹងពេលណាលែងនឹកអូន

បើមិនដែលសូន្យរូបកល្យាណ

ជាប់បេះដូងបងហួសការស្មាន

អាចទេដើមដានរលត់ទៅ។

ទោះអូនចាត់ទុកបងជាអ្វី

គូស្នេហមិត្រក្តីស្រេចតែពៅ

បងមិនកែឡើយទោះខុសត្រូវ

ស្នេហយើងតម្រូវចប់បែបនេះ៕៚

ដោយ តៃ សុវណ្ណារុណ

សៅរ, ២២:៤២-២៣:១៤, ១៥/០៦/២០១៣